# អ្នកដើរតាមព្រះគ្រីស្ទ

អែលឌើរ វ៉លធើរ អែហ្វ ហ្គុងស្សាឡែស្ស
ក្នុងគណៈប្រធាននៃពួកចិតសិបនាក់

*ពួកអ្នកដើរតាមផ្លូវរបស់ព្រះគ្រីស្ទ ជីវិតរបស់ពួកគេនៅជាមួយនឹងព្រះអង្គសង្គ្រោះ ហើយដើរនៅក្នុងពន្លឺ ។*

កាលពីខែតុលាឆ្នាំមុន ភរិយារបស់ខ្ញុំ ហើយនិងខ្ញុំបានរួមដំណើរនឹងអែលឌើរ និងស៊ីស្ទើរអាន់ឌើរសិន ដើម្បីចូលរួមការបើកសម្ពោធព្រះ -វិហារបរិសុទ្ធថ្មី នៅក្នុង ទីក្រុងខ័រដូបា ប្រទេស អាហ្សង់ទីន ។ តាមទំនៀមទម្លាប់ ត្រូវមានការធ្វើសន្និសីទកាសែតបន្ទាប់ពីពិធីនោះ ។ មានអ្នកសារ -ព័ត៌មានមួយរូប ដែលមិនមែនជាសមាជិកនៃសាសនាចក្រ បានចាប់ផ្ដើមនិយាយថាពួកបុរសៗអីក៏ល្អម្ល៉េះដែលបានធ្វើយ៉ាងល្អចំពោះភរិយាខ្លួន ។ បន្ទាប់មកគាត់បានសួរសំណួរដែលនឹកស្មានមិនដល់មួយថា ៖ តើវាជាការពិត ឬជាការធ្វើពុត ? ខ្ញុំជឿជាក់ថាគាត់បានឃើញ និងដឹងថាអ្វីមួយខុសប្លែកក្នុងសមាជិកយើង។ គាត់ប្រហែលជាសង្កេតមើលបំណងប្រាថ្នា របស់សមាជិកយើង ដើម្បីធ្វើតាមព្រះគ្រីស្ទ ។ សមាជិកសាសនាចក្រទូទាំងពិភពលោក មានបំណងប្រាថ្នានេះ ។ នៅក្នុងពេលស្របគ្នានោះ ក៏មនុស្សរាប់លាននាក់ដែលពុំមែនជាសមាជិកនៃសាសនាចក្រដែលមានបំណងប្រាថ្នាដើរតាមទ្រង់ផងដែរ ។

ថ្មីៗនេះ ភរិយារបស់ខ្ញុំ ហើយខ្ញុំបានមានចិត្តស្ញើចសរសើរដល់សមាជិកដែលយើងឃើញនៅ ហ្គាណា និងនីហ្សេរីយ៉ា ។ ភាគច្រើនពុំមែនជាសមាជិកសាសនាចក្ររបស់យើងឡើយ ។ យើងសប្បាយរីករាយដែលឃើញពីបំណងប្រាថ្នារបស់ពួកគេដើម្បីធ្វើតាមព្រះគ្រីស្ទ ដែលបានថ្លែងឡើងនៅក្នុងការសន្ទនារបស់ពួកគេជាច្រើន នៅក្នុងផ្ទះ លើឡាន លើជញ្ជាំង និងនៅលើផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្មរបស់ពួកគេ ។ យើងពុំដែលបានឃើញពួកគ្រីស្ទានជាច្រើនដែលរស់នៅជិតគ្នាដូចនេះ នោះទេ ។

ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ កាតព្វកិច្ចរបស់យើងគឺត្រូវអញ្ជើញមនុស្សរាប់លាននាក់ ដូចជាពួកគេដូច្នេះ ដើម្បីឲ្យពួកគេមក និងបានឃើញនូវអ្វីដែលសាសនាចក្ររបស់យើងអាចបន្ថែមទៅលើរឿងល្អៗដែលពួកគេបានមានរួចទៅហើយនោះ ។ ទោះជាមនុស្សនោះមកពីទ្វីបណា រស់នៅក្នុងអាកាសធាតុបែបណា ឬវប្បធម៌បែបណាក្ដី ក៏អាចដឹងថា ព្យាការី យ៉ូសែប ស្ម៊ីធ បានឃើញព្រះវរបិតា និងព្រះរាជបុត្រានៅក្នុងទស្សននិមិត្តដែរ ។

ពួកគេអាចដឹងថា សារទូតពីស្ថានសួគ៌បានស្ដារបព្វជិតភាពឡើងវិញ ហើយថាព្រះគម្ពីរមរមន គឺជាសក្ខីបទមួយទៀតពីព្រះយេស៊ូវគ្រីស្ទ ។ ក្នុងសំដីរបស់អេណុសថា « ... សេចក្ដីសុចរិត [ ត្រូវបានចាត់ ] ពីស្ថានសួគ៌ និងសេចក្ដីពិត [ ត្រូវបានចាត់ ] ចេញពីផែនដី ដើម្បីទៅ [ធ្វើទីបន្ទាល់] ពីព្រះរាជបុត្រាបង្កើតតែមួយ [ របស់ព្រះវរបិតា ] របស់យើង » ។ [1]

ព្រះអង្គសង្គ្រោះបានសន្យាថា ៖ « ...អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្ដីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ » ។ [2] ពួកអ្នកដើរតាមផ្លូវរបស់ព្រះគ្រីស្ទ ជីវិតរបស់ពួកគេនៅជាមួយនឹងព្រះអង្គសង្គ្រោះ ហើយដើរនៅក្នុងពន្លឺ ។ មានលក្ខណៈពីរយ៉ាងដែលអាចជួយយើងឲ្យស្គាល់នូវចំណុចដែលយើងត្រូវធ្វើតាមទ្រង់ ។ ទីមួយ ពួកអ្នកដើរតាមព្រះគ្រីស្ទ គឺចេះស្រឡាញ់មនុស្សដទៃ ។ ទីពីរ ពួកអ្នកដើរតាមព្រះគ្រីស្ទ ធ្វើ និងរក្សានូវសេចក្ដីសញ្ញាទាំងឡាយ ។

លក្ខណៈទីមួយ ការចេះស្រឡាញ់គ្នា គឺប្រហែលជារឿងមួយដែលអ្នកសារព័ត៌មាននៅ ខ័រដូបា បានសង្កេតឃើញនៅក្នុងចំណោមសមាជិកសាសនាចក្ររបស់យើង ។ យើងធ្វើតាមព្រះគ្រីស្ទពីព្រោះយើងស្រឡាញ់ទ្រង់ ។ នៅពេលដែលយើងធ្វើតាមសេចក្ដីស្រឡាញ់របស់ព្រះប្រោសលោះ គឺមានន័យថាយើងកំពុងតែធ្វើតាមគំរូរបស់ទ្រង់ផ្ទាល់ ។ តាមរយៈក្ដីស្រឡាញ់ ព្រះអង្គសង្គ្រោះបានគោរពប្រតិបត្តិតាមព្រះទ័យរបស់ព្រះវរបិតា នៅគ្រប់កាលៈទេសៈទាំងអស់ ។ ព្រះអង្គសង្គ្រោះរបស់យើងបានគោរពប្រតិបត្តិ ទោះបីជាត្រូវមានការឈឺចាប់ខាងរូបកាយ ឬខាងស្មារតីខ្លាំងយ៉ាងណាក្ដី ទោះបីជាទ្រង់ត្រូវគេវាយនឹងខ្សែតី ឬសើចចំអកក្ដី ទោះបីជាមានពួកអ្នកស្អប់ទ្រង់នឹងធ្វើទារុណកម្មទ្រង់ ខណៈដែលមិត្តភក្តិរបស់ទ្រង់បោះបង់ទ្រង់ចោលក៏ដោយ ។ ការពលិកម្មដ៏ធ្ងន់ ដែលមានន័យដូចនឹងបេសកកម្មរបស់ព្រះអង្គសង្គ្រោះ គឺជាការបង្ហាញសេចក្ដីស្រឡាញ់ដ៏មហិមាជាងគេបំផុត ។ « ... ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជាដោយសារស្នាមរំពាត់នៅអង្គទ្រង់ » [3]

យើងគួរតែធ្វើតាមព្រះរាជបុត្រារបស់ទ្រង់ ដូចជាព្រះគ្រីស្ទ បានធ្វើតាមព្រះវរបិតា មិនថាក្នុងស្ថានភាពណាទេ ។ បើយើងធ្វើដូច្នោះ មិនថាទុក្ខការបៀតបៀនបែបណា ការឈឺចាប់ ការទួញសោកបែបណា ឬបន្លាត្រូវចាក់ចូលក្នុងសាច់[4] ដែលយើងកំពុងប្រឈមមុខនោះទេ។ យើងមិននៅម្នាក់ឯងនោះទេ ។ ព្រះគ្រីស្ទនឹងជួយយើង ។ សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់ និងធ្វើឲ្យយើងខ្លាំងពូកែ នៅគ្រប់ស្ថានភាពទាំងអស់ ។[5]

ការធ្វើតាមព្រះគ្រីស្ទអាចមានន័យថា ជាការលះបង់នូវរបស់ជាទីស្រឡាញ់ជាច្រើន ដូចជា នាងរស់ ស្រុកម៉ូអាប់បានធ្វើ ។ ជាសេចក្តីសញ្ញាថ្មី ចេញមកពីសេចក្តីស្រឡាញ់ចំពោះព្រះ និងនាងន៉ាអូមី នាងបានចាកចោលអ្វីៗ ដើម្បីរស់នៅតាមសាសនារបស់នាង ។[6] វាក៏អាចមានន័យផងដែរថាជា ការទប់ទល់នឹងមាសត្រូវ និងការល្បួង ។ ក្នុងយុវវ័យរបស់គាត់ យ៉ូសែប ត្រូវបានលក់ទៅជាឈ្លើយ ។ គាត់ត្រូវបានគេដកយកអ្វីៗដែលគាត់ស្រឡាញ់ ។ ក្រោយមកគាត់ត្រូវបានល្បួងឲ្យប្រព្រឹត្តអំពើកំផិត ។ គាត់បានជំទាស់នឹងការល្បួង ហើយនិយាយថា « . . . ធ្វើដូចម្តេចឲ្យខ្ញុំប្រព្រឹត្តការដែលអាក្រក់យ៉ាងធំនេះទៅបាន ធ្វើយ៉ាងនោះនឹងមានបាបនៅចំពោះព្រះផង ? »[7] សេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះ មានអំណាចខ្លាំងជាងមាសត្រូវ និងការល្បួងទាំងឡាយ ។

សព្វថ្ងៃនេះ យើងមាននាងរស់ និងយ៉ូសែប សម័យទំនើប នៅទូទាំងពិភពលោក ។ នៅពេលបងប្រុស ជិមមី អូលវ៉េរ៉ា មកពី ហ្គាយ៉ាហ្គិល ប្រទេស អេក្វាឌ័របានទទួលការហៅឲ្យបម្រើបេសកកម្មរបស់គាត់ គ្រួសាររបស់គាត់ កំពុងតែមានបញ្ហាលំបាកយ៉ាងខ្លាំង ។ នៅថ្ងៃដែលគាត់ចាកចេញ គាត់ត្រូវបានប្រាប់ថា បើគាត់ដើរចេញពីមាត់ទ្វារ គាត់នឹងបាត់បង់គ្រួសារហើយ ។ គាត់បានដើរចេញទៅដោយដួងចិត្តខ្ទេចខ្ទាំ ។ ក្នុងបេសកកម្មរបស់គាត់ ម្តាយរបស់គាត់បានសុំឲ្យគាត់នៅបម្រើបេសកកម្មឲ្យបានយូរទៀត ពីព្រោះពួកគេកំពុងតែទទួលបានពរជ័យ ច្រើនណាស់ ។ សព្វថ្ងៃនេះ អូលវ៉េរ៉ា បម្រើជាលោកអយ្យកោក្នុងស្តេកមួយ ។

សេចក្តីស្រឡាញ់ដ៏ពិតរបស់ព្រះគ្រីស្ទផ្តល់កម្លាំងដែលត្រូវការដើម្បីធ្វើតាមទ្រង់ ។ ព្រះអម្ចាស់ទ្រង់ផ្ទាល់បានបង្ហាញការណ៍នេះពេលទ្រង់បានសួរពេត្រុសបីដងថា « តើស្រឡាញ់ខ្ញុំទេឬអី ? » ។ បន្ទាប់មក ពេត្រុសបានបញ្ជាក់យ៉ាងច្បាស់ថា គាត់ស្រឡាញ់ព្រះអម្ចាស់ ។ ព្រះអម្ចាស់ ប្រាប់ពេ -ត្រុសអំពីការលំបាកដែលនឹងមកដល់ ។ បន្ទាប់មកការអញ្ជើញក៏សុំឲ្យគាត់ « ធ្វើតាមទ្រង់ » ។ សំណួររបស់ព្រះអង្គសង្គ្រោះដែលបានសួរពេត្រុស អាចត្រូវបានសួរមកយើងផងដែរថា ៖ « តើស្រឡាញ់ខ្ញុំទេឬអី ? » ដែលត្រូវបានអញ្ជើញឲ្យធ្វើជាសកម្មភាពថា ៖ « ធ្វើតាមទ្រង់ » ។[8]

សេចក្តីស្រឡាញ់គឺមានឥទ្ធិពលខ្លាំងណាស់នៅក្នុងការខិតខំរបស់យើងដើម្បីប្រតិបត្តិតាម ។ សេចក្តីស្រឡាញ់ចំពោះព្រះអង្គសង្គ្រោះរបស់យើងបំផុសឲ្យយើងរក្សាព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ សេចក្តីស្រឡាញ់ចំពោះអ្នកដទៃក៏អាចបំផុសឲ្យយើងមានការគោរពចំពោះគោលការណ៍ទាំងឡាយនៃដំណឹងល្អផងដែរ ។ តាមរយៈរបៀបដែលយើងប្រព្រឹត្តចំពោះអ្នកដទៃឆ្លុះបញ្ចាំងពីគំរូដែលយើងធ្វើតាមព្រះអង្គសង្គ្រោះរបស់យើង នៅក្នុងការស្រឡាញ់ដល់អ្នកដទៃ ។[9] យើងបង្ហាញក្តីស្រឡាញ់របស់យើងចំពោះទ្រង់ នៅពេលដែលយើងឈប់ជួយអ្នកដទៃ ពេលដែលយើង « ស្មោះត្រង់ទាំងស្រុង និងទៀងត្រង់នៅគ្រប់រឿង »[10] និងនៅពេលយើងចុះ និងរក្សាសេចក្តីសញ្ញាទាំងឡាយ ។

លក្ខណៈទីពីរដែលពួកអ្នកដើរតាមព្រះគ្រីស្ទមាន គឺការចុះ និងរក្សាសេចក្តីសញ្ញាទាំងឡាយ ។ មរ៉ូណៃបានបង្ហាញថា « ... ដោយការច្រូចព្រះលោហិតនៃព្រះគ្រីស្ទ ... មាននៅក្នុងសេចក្តីសញ្ញានៃព្រះវរបិតា ចំពោះការផ្តាច់បាបដល់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានបរិសុទ្ធ ដោយគ្មានប្រឡាក់អ្វីសោះឡើយ » ។[11]

ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនថា សូម្បីតែពីមុនការបង្កើតផែនដី ក៏សេចក្តីសញ្ញាទាំងឡាយត្រូវបានបង្កើតនៅស្ថានសួគ៌រួចទៅហើយ ។[12] បន្ទាប់មកពួកព្យាការី និងពួកអយ្យកោពីបុរាណ បានចុះសេចក្តីសញ្ញាទាំងឡាយ។

ព្រះអង្គសង្គ្រោះទ្រង់ផ្ទាល់បានធ្វើជាគំរូ ។ ទ្រង់ទទួលពិធីបុណ្យជ្រមុជទឹកដើម្បីបំពេញរាល់សេចក្តីសុចរិត ពីបុគ្គលដែលមានសិទ្ធិអំណាចត្រឹមត្រូវ ។ តាមរយៈបុណ្យជ្រមុជទឹករបស់ទ្រង់ ព្រះអង្គសង្គ្រោះបានធ្វើជាសាក្សីដល់ព្រះវរបិតាថា ទ្រង់នឹងគោរពប្រតិបត្តិនូវរាល់ព្រះបញ្ញត្តិរបស់ព្រះវរបិតាទាំងអស់ ។[13] ដូចជានៅសម័យបុរាណ យើងក៏ដើរតាមព្រះគ្រីស្ទ ហើយចុះសេចក្តីសញ្ញាទាំងឡាយតាមរយៈពិធីការនៃបព្វជិតភាព។ ការចុះសេចក្តីសញ្ញាទាំងឡាយ គឺជាអ្វីមួយដែលមនុស្សរាប់លាននាក់ ដែលមិនមែនជាសមាជិកនៃសាសនាចក្ររបស់យើង អាចបន្ថែមទៅក្នុងរឿងល្អៗ ដែលពួកគេមានរួចទៅហើយ ។ ការចុះ សេចក្តីសញ្ញាទាំងឡាយ គឺជាការបង្ហាញសេចក្តីស្រឡាញ់ ។ វាជារបៀបមួយដែលទូលទៅកាន់ទ្រង់ថា បាទ ឬ ចាស ខ្ញុំនឹងដើរតាមទ្រង់ ។

សេចក្ដីសញ្ញាទាំងឡាយ មាននូវសេចក្ដីសន្យាទាំងឡាយ « ... ជាជីវិតដ៏នៅអស់កល្បជានិច្ច » [14] ។ អ្វីគ្រប់យ៉ាងនឹងកើតឡើងសម្រាប់សេចក្ដីល្អរបស់យើង បើសិនជាយើងចងចាំសេចក្ដីសញ្ញារបស់យើង ។ [15] ពួកគេត្រូវតែចុះ និងរក្សាសេចក្ដីសញ្ញា ដើម្បីទទួលបានការសន្យាពេញលេញ ដែលនឹងផ្ដល់ឲ្យ ។ សេចក្ដីស្រឡាញ់ចំពោះព្រះអង្គសង្គ្រោះ និងការចងចាំដល់សេចក្ដីសញ្ញារបស់យើងនឹងជួយយើងរក្សាសេចក្ដីសញ្ញា ។ ការទទួលទាននូវសាក្រាម៉ង់ គឺជាវិធីមួយដើម្បីចងចាំសេចក្ដីសញ្ញារបស់យើង ។[16]

វិធីមួយទៀតគឺត្រូវចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធឲ្យបានញឹកញាប់ ។ ខ្ញុំនៅចងចាំពីស្វាមីភរិយាថ្មីថ្មោងមួយគូដែលរស់នៅអាមេរិកខាងត្បូង ដែលចង់លែងលះគ្នា ព្រោះពួកគេពុំចុះសម្រុងនឹងគ្នា ។ មានអ្នកដឹកនាំបព្វជិតភាពដ៏ឈ្លាសវៃមួយរូបបានប្រឹក្សាឲ្យពួកគេចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធ និងផ្ដោតយកចិត្តទុកដាក់ជាពិសេសទៅលើពាក្យសំដី និងសេចក្ដីសន្យានៃសេចក្ដីសញ្ញាទាំងឡាយដែលបានធ្វើនៅទីនោះ ។ គូស្វាមីភរិយានោះក៏បានធ្វើដូច្នោះ ហើយបានរក្សាអាពាហ៍ពិពាហ៍របស់ពួកគេ ។ អំណាចនៃសេចក្ដីសញ្ញារបស់យើង គឺមហិមាជាងឧបសគ្គដែលយើងប្រទះ ។

ចំពោះសមាជិកដែលមិនសកម្មនៅក្នុងសាសនាចក្រ សូមត្រឡប់មកវិញ។ សូមទទួលអារម្មណ៍ចងចាំ និងរំលឹកឡើងវិញនូវសេចក្ដីសញ្ញាទាំងឡាយតាមរយៈពិធីសាក្រាម៉ង់ និងការចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធ ។ ការធ្វើបែបនោះគឺជាការបង្ហាញមួយនូវសេចក្ដីស្រឡាញ់ និងការបង្ហាញនូវឆន្ទៈ ដើម្បីក្លាយជាអ្នកដើរតាមដ៏ពិតនៃព្រះគ្រីស្ទ ។ ការធ្វើបែបនោះនឹងធ្វើឲ្យអ្នកមានគុណសម្បត្តិក្នុងការទទួលនូវពរជ័យដែលបានសន្យាទាំងអស់ ។
ចំពោះសមាជិកទាំងឡាយណាដែលពុំមែនជាសមាជិកនៃសាសនាចក្រ ខ្ញុំសូមអញ្ជើញអ្នកឲ្យអនុវត្តសេចក្ដីជំនឿ ការប្រែចិត្ត និងធ្វើឲ្យមានគុណសម្បត្តិ ដើម្បីទទួលសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹកនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ តាមរយៈការធ្វើដូច្នោះ អ្នកនឹងបង្ហាញសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះវរបិតាសួគ៌ និងឆន្ទៈរបស់អ្នកដើម្បីធ្វើតាមព្រះគ្រីស្ទ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថាយើង គឺមានភាពសប្បាយរីករាយជាងនៅពេលយើងធ្វើតាមការបង្រៀនទាំងឡាយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលដែលយើងព្យាយាមធ្វើតាមទ្រង់ ពរជ័យនៃស្ថានសួគ៌នឹងធ្លាក់មកលើយើង ។ ខ្ញុំដឹងថាសេចក្ដីសន្យារបស់ទ្រង់នឹងត្រូវបានបំពេញ ដរាបណាយើងចុះ និងរក្សាសេចក្ដីសញ្ញាទាំងឡាយ ហើយប្រែក្លាយជាអ្នកដើរតាមយ៉ាងពិតប្រាកដរបស់ព្រះគ្រីស្ទ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ពីសេចក្ដីពិតដ៏មហិមាសម្រាប់យើងម្នាក់ៗ ហើយសូមធ្វើអ្វីៗទាំងនេះនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ម៉ូសេ 7:62 ។
2. យ៉ូហាន 8:12 ។
3. អេសាយ 53:5 ។
4. កូរិនថូសទី 2 12:7 ។
5. នីហ្វៃទី1 1:20 ។
6. នាងរស់ 1:16 ។
7. លោកុប្បត្តិ 39:7--9 ។
8. យ៉ូហាន 21:15–19 ។
9. យ៉ូហាន 13:35 ។
10. អាលម៉ា 27:27 ។
11. មរ៉ូណៃ 10:33 ។
12. សូមមើល *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ 2007 ) ទំព័រ 42 សូមមើលផងដែរ Spencer W. Kimball « Be Ye Therefore Perfect »( សុន្ទរកថាដែលត្រូវបានធ្វើឡើងនៅឯសាកលវិទ្យាល័យយូថាហ៍ វិទ្យាស្ថានអិល.ឌី.អេស. នៃសាសនា ថ្ងៃទី 10 ខែ មករា ឆ្នាំ1975 ៖ « យើងបានធ្វើសម្បថ ដែលជាពាក្យសម្បថដ៏ធំ នៅលើស្ថានសួគ៌ពីយើងបានមកចាប់កំណើតនៅក្នុងជីវិតរមែងស្លាប់នេះ ...។ យើងបានចុះសេចក្ដីសញ្ញា ។ យើងបានចុះសេចក្ដីសញ្ញាទាំងនោះ ពីមុនយើងបានទទួលយកតួនាទីរបស់យើងនៅលើផែនដីនេះទៅទៀត ... » ) ។
13. នីហ្វៃទី 2 31:5-7 ។

14. អ័ប្រាហាំ 2:11 សូមមើលផងដែរ John A. Widtsoe « Temple Worship » ( lecture, Assembly Hall, Salt Lake City ថ្ងៃទី 12 ខែ តុលា ឆ្នាំ 1920 ) ទំព័រ 10 ៖ ( « សេចក្ដីសញ្ញាផ្ដល់ជីវិតនូវសេចក្ដីពិត ហើយធ្វើឲ្យជីវិតអាចទទួលពរជ័យ ដែលផ្ដល់រង្វាន់ ដល់អ្នកទាំងឡាយ ដែលប្រើចំណេះដឹងដោយត្រឹមត្រូវ . . . » ) ។

15. គ. និង ស. 90:24 ។

16. ឧ. នីហ្វៃទី3 18:7–11 ។